រដ្ឋាភិបាល ។

- ឯកឧត្តម អៀង សុខ ទទួលបន្ទុកកិច្ចការសារពត៌មាន និងនយោបាយសាធារណៈ
- ឯកឧត្តម អ៊ុង ធី ទទួលបន្ទុកច្បាប់ និងកិច្ចការរបស់រដ្ឋសភា ។
- ឯកឧត្តម សួស យារ៉ាណាន់ ទទួលបន្ទុកកិច្ចការជនជាតិ និងធម្មការ ។
- ឯកឧត្តម សយ ស៊ីផុន ទទួលបន្ទុកកិច្ចការសហជីព និងអង្គការសង្គម ។

**មាត្រា ២** : នាយករដ្ឋមន្ត្រីទី ១ និងនាយករដ្ឋមន្ត្រីទី ២ នៃរាជរដ្ឋាភិបាលកម្ពុជា ព្រមទាំងអគ្គលេខាធិការរបស់រដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះអោយបានសំរេច ។

**មាត្រា ៣** : ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់តាំងពីថ្ងៃឡាយព្រះហស្ថលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ,ថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ១៩៩៥

**ក្នុងព្រះបរមនាម និងតាមព្រះរាជបញ្ជាសំបទ្ទាប់**

ប្រមុខរដ្ឋស្តីទី

**ជា ស៊ីម**

## II- ពិធីស្តីការគណៈរដ្ឋមន្ត្រី

### ១- អនុក្រឹត្យ

រាជធានីភ្នំពេញ ,ថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ១៩៩៥

**អនុក្រឹត្យលេខ ៥៨ អ.ន.ក្រ**

**ស្តីពី**

**ការបង្កើតគណៈកម្មការអោយតំលៃដីមិនបានប្រើប្រាស់**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុវរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

www.pheakdeylaw.com

- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ១០៩៤.៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១១ នស.៩៤ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤
- តាមសំណើរបស់ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**សំរេច**

**មាត្រា ១ :** បង្កើតគណៈកម្មការមួយមានឈ្មោះថា គណៈកម្មការវាយតំលៃដីមិនបានប្រើប្រាស់ ដែលមានសមាសភាពដូចខាងក្រោម :

| | |
|---|---|
| - រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឬអ្នកតំណាង | ជាប្រធាន |
| - ប្រធានគណៈកម្មាធិការជាតិរៀបចំទឹកដីនគរូបនីយកម្ម និងសំណង់ ឬអ្នក តំណាង | ជាអនុប្រធាន |
| - ប្រធាននាយកដ្ឋានពន្ធដារ ឬអ្នកតំណាង | ជាសមាជិក |
| - ប្រធាននាយកដ្ឋានទ្រព្យរដ្ឋ ឬអ្នកតំណាង | ជាសមាជិក |
| - ប្រធាននាយកដ្ឋានសុរិយោដី ឬអ្នកតំណាង | ជាសមាជិក |

**មាត្រា ២ :** គណៈកម្មការនេះមានភារកិច្ចដូចខាងក្រោម :

- បង្កើតបញ្ជីរាយឈ្មោះទីក្រុង និងតំបន់ដែលមានដីត្រូវជាប់ពន្ធ
- កំណត់ប្រចាំឆ្នាំនូវតំលៃដីក្នុងមួយម៉ែត្រក្រឡា
- ផ្តល់មតិចំពោះរឿងវិវាទ

**មាត្រា ៣ :** គណៈកម្មការនេះមានសិទ្ធិចាត់តាំងអនុគណៈកម្មការនៅតាមខេត្តក្រុងនិមួយៗ សំរាប់ជំនួយការក្នុងការអនុវត្តន៍ភារកិច្ចខាងលើ ។

**មាត្រា ៤ :** គណៈកម្មការវាយតំលៃដីមិនបានប្រើប្រាស់ មានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីអនុវត្តភារកិច្ចរបស់ខ្លួន ។

**មាត្រា ៥ :** សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ប្រធានគណៈកម្មាធិការជាតិរៀបចំទឹកដីនគរូបនីយកម្ម និងសំណង់ និងអស់លោកដូចមានចែងក្នុងមាត្រា ១ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃ

www.pheakdeylaw.com

ឡាយព្រះហស្តលេខា និងចុះហត្ថលេខាដោយ

នាយករដ្ឋមន្ត្រីទី ១ នាយករដ្ឋមន្ត្រីទី ២

ព្រះហស្តលេខា និងត្រា ហត្ថលេខា និងត្រា

**នរោត្តម រណឫទ្ធិ** **ហ៊ុន សែន**

រាជធានីភ្នំពេញ, ថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ១៩៩៥

## អនុក្រឹត្យលេខ ៥៩ អនក្រ.បក

## ស្តីពីប្រាក់បំណាច់សំរាប់សមាជិករាជរដ្ឋាភិបាល

## អនុរដ្ឋលេខាធិការ និងទីប្រឹក្សា

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុវរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុវរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងអនុរដ្ឋលេខាធិការ នៅតាមក្រសួងស្ថាប័ន និងរដ្ឋលេខាធិការដ្ឋាន
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- យោងតាមសំណូមពររបស់រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- យោងសេចក្តីសំរេចនៃកិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី នៅថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ១៩៩៥

### សំរេច

**មាត្រា ១**.- ផ្តល់ប្រាក់បំណាច់បន្ថែមពីលើប្រាក់បៀវត្សប្រចាំខែ ជូនសមាជិករាជរដ្ឋាភិបាល ដែលមិនមែនជាសមាជិកសភា អនុរដ្ឋលេខាធិការ នៃក្រសួង រដ្ឋលេខាធិការដ្ឋាន ទីប្រឹក្សា

www.pheakdeylaw.com